**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

# លិខិតជូនពរ

**សូមគោរពជូន**
**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

ក្នុងឱកាសដ៏មហាប្រសើរប្រកបដោយក្ដីសោមនស្សរីករាយ នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈ សូមសម្ដែងនូវអំណរសាទរយ៉ាងក្លៀវក្លាក្រៃលែង និងសូមគោរពជូនពរ បវរសួស្ដី សិរីមង្គល វិបុលសុខ ដ៏មហាប្រសើរគ្រប់ប្រការ ជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** សូមមានសុខភាពល្អបរិបូរណ៍ បញ្ញាញាណភ្លឺថ្លា កាយពលមាំមួន និងជន្មាយុយឺនយូរ ដើម្បីបន្តដឹកនាំក្រុមប្រឹក្សាធម្មនុញ្ញ ឱ្យសម្រេចបាននូវជ័យជម្នះធំៗជាច្រើនថែមទៀត ដើម្បីចូលរួមចំណែកយ៉ាងសំខាន់ដល់ដំណើរការនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍរបស់ប្រទេសជាតិឱ្យកាន់តែមានភាពសម្បូរសប្បាយ និងសុភមង្គល ជូនប្រជាជាតិខ្មែរនៅក្រោមដំបូលនៃសុខសន្តិភាព និងភាតរភាពជាតិ។

ឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លា នៃពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ យើងខ្ញុំទាំងអស់គ្នា សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ និងវត្ថុស័ក្ដិសិទ្ធិទាំងអស់ក្នុងលោក តេជៈបារមីទេវតារក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងទេវតាឆ្នាំថ្មី ព្រះនាម **កិមិរាទេវី** សូមយាងប្រោសប្រទានសព្ទសាធុការពរជូន **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត និងលោកជំទាវ ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី** មានសុខភាពល្អបរិបូរណ៍ បវរសួស្ដី សិរីមង្គលគ្រប់ប្រការ និងសូមសមប្រកបនឹងព្រះពុទ្ធពរដ៏មហាប្រសើរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំទាំងអស់គ្នា៕

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣
**តំណាងថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈ**
**រដ្ឋមន្ត្រី**

ព្រុំ.សុខា